UNDP

Empowered lives.
Resilient nations.

# ព្រឹត្តិបត្រព័ត៌មាន

លេខ ៤១
ខែមីនា ឆ្នាំ ២០១៤

*យូអិនឌីភី ធ្វើដៃគូជាមួយប្រជាជនគ្រប់ស្រទាប់សង្គមក្នុងការជួយប្រជាជាតិឲ្យមានភាពស្ថិតស្ថេរទប់ទល់នឹងវិបត្តិ ជំរុញ និងរក្សាចីរភាពកំណើន សំដៅលើកស្ទួយគុណភាពនៃជីវភាពសម្រាប់ទាំងអស់គ្នា។ យើងមានវត្តមានក្នុងប្រទេសនិងដែនដីជាង ១៧០ ហើយយើងប្រើប្រាស់ទស្សនវិស័យសកល និងក្នុងស្រុក ដើម្បីជួយប្រជាជន និងប្រជាជាតិកសាងជីវភាពឲ្យបានកាន់តែប្រសើរ និងរឹងមាំថែមទៀត។*

## យុទ្ធសាស្ត្រពាណិជ្ជកម្មរបស់កម្ពុជា ដោះស្រាយគម្លាតខាងជំនាញដើម្បីពង្រឹងភាពប្រកួតប្រជែង

**ភ្នំពេញ** - កម្ពុជាបានចេញផ្សាយយុទ្ធសាស្ត្រពាណិជ្ជកម្មថ្មីមួយដែលផ្តោតការយកចិត្តទុកដាក់លើភាពចាំបាច់ដើម្បីបង្កើនជំនាញរបស់ពលករ សំដៅពង្រឹងភាពប្រកួតប្រជែងខាងការនាំចេញរបស់ប្រទេស និងការបង្កើតការងារទៅអនាគត។

ការដោះស្រាយភាពខ្វះចន្លោះខាងជំនាញគឺជាអាទិភាពបន្ទាន់មួយ ជាពិសេស នៅពេលដែលសហគមន៍សេដ្ឋកិច្ចនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន)នៅឆ្នាំ ២០១៥ កាន់តែឈានជិតមកដល់។ នៅក្នុងពេលប្រកាសយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា (Cambodia Trade Integration Strategy/CTIS) ឆ្នាំ២០១៤-២០១៨ កាលពីថ្ងៃទី ១៨ កុម្ភៈ កន្លងទៅនេះ មន្ត្រីរដ្ឋាភិបាល និងតំណាងអង្គការសហប្រជាជាតិបាននិយាយថា សមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់រួមផ្សំជាមួយយុវជនកម្ពុជាចំនួន ៤០០.០០០នាក់ដែលរំពឹងថាចូលក្នុងទីផ្សារការងារជារៀងរាល់ឆ្នាំ វាមិនត្រឹមតែជាឱកាសប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការប្រឈមសម្រាប់ប្រទេសផងដែរ។

ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម មានប្រសាសន៍នៅក្នុងពិធីនោះថា "យុទ្ធសាស្ត្រនេះនឹងជួយយើងកៀងគរជំនួយបច្ចេកទេសថ្មីៗ ដើម្បីដោះស្រាយកំណែទម្រង់ថ្មីៗដែលយើងត្រូវអនុវត្ត។ លើសពីនេះ យុទ្ធសាស្ត្រនេះនឹងជួយពង្រឹងភាពប្រកួតប្រជែងនៃវិស័យពាណិជ្ជកម្ម បង្កើតរបរថ្មីៗ បង្កើនប្រាក់ចំណូល និងកាត់បន្ថយភាពក្រីក្រផងដែរ"។

យុទ្ធសាស្ត្រ CTIS បានធ្វើបច្ចុប្បន្នភាពចំនួនបីលើករួចមកហើយគិតចាប់ពីឆ្នាំ ២០០១មក នៅ

*តទៅទំព័រទី ២*

## មាតិកា

ពីដីធ្លាប់មានគ្រាប់មីនទៅជាទីសុវត្ថិភាពសម្រាប់ដាំដំណាំ........................................២
យុវជនស្វែងយល់ដឹងជាងមុនអំពីជីវភាពជាពលរដ្ឋស៊ីវិល..........................................៣
ផ្តើមដំណើរការគម្រោងត្រៀមលក្ខណៈដើម្បី REDD+ ..........................................៣
សមភាពសម្រាប់ស្ត្រី គឺជាវឌ្ឍនភាពសម្រាប់ទាំងអស់គ្នា! .........................................៤

## បន្ទះស្រូបពន្លឺព្រះអាទិត្យនាំថាមពលបំភ្លឺគេហដ្ឋាននៅជនបទ



Photo: UNDP Cambodia

*អ្នកភូមិកំពុងលាងសំអាតបន្ទះ ស្រូបពន្លឺព្រះអាទិត្យដើម្បីសាកអាគុយយកអគ្គីសនីសម្រាប់ប្រើប្រាស់ នៅភូមិត្របែក ខេត្តកំពង់ឆ្នាំង។*

**កំពង់ឆ្នាំង**-ការប្រើប្រាស់ម៉ាស៊ីនភ្លើងដើម្បីបញ្ចូលអាគុយ គឺជាវិធីទូទៅសម្រាប់គ្រួសារនានាតាមជនបទដែលនៅតែមិនទាន់បានតភ្ជាប់ទៅបណ្តាញអគ្គិសនីជាតិ។ ប៉ុន្តែនៅខេត្តកំពង់ឆ្នាំង សេវាកម្មបែបនេះត្រូវបានជំនួសដោយវិធីមួយដែលមានបច្ចេកវិទ្យាខ្ពស់ជាងមុន។

នៅភូមិពោធិ៍ និងភូមិត្របែក ដែលស្ថិតក្នុងឃុំកំពុងលែងក្នុងបឹងទន្លេសាបបន្ទះស្រូបពន្លឺព្រះអាទិត្យបានបម្លែងពន្លឺទៅជាថាមពលអគ្គិសនីនិងបញ្ជូនចរន្តនេះតាមខ្សែភ្លើងដែលតភ្ជាប់ទៅអាគុយនៅខាងក្រោម។ បច្ចេកវិទ្យានេះបានមកជំនួសម៉ាស៊ីនភ្លើងដែលបន្លឺស្នូរជាខ្លាំង និងបំភាយកាបូនដែលពីមុនអ្នកភូមិពីរនេះធ្លាប់ប្រើប្រាស់ជាមធ្យោបាយដើម្បីផលិតថាមពល។

ភេម ដា ស្ត្រីអាយុ ៦៩ឆ្នាំ នៅភូមិពោធិ៍បានពោលថា "សប្បាយចិត្តណាស់ ដោយអាគុយរបស់ខ្ញុំក៏កាន់ភ្លើងបានយូរទៀតផង ក្រោយពីបញ្ចូលម្តងៗតាមប្រព័ន្ធថាមពលព្រះអាទិត្យ។"

នៅម្ខាងផ្លូវទល់មុខផ្ទះរបស់អ៊ុំស្រីភេម ដា លោក ជួប ផា អាយុ ៥៧ឆ្នាំ ធ្លាប់ប្រើប្រាស់ម៉ាស៊ីនភ្លើងសម្រាប់បញ្ចូលអាគុយដែលជារបរចិញ្ចឹមជីវិតរបស់គាត់។ សព្វថ្ងៃនេះ គាត់គ្រប់គ្រងស្ថានីយ៍ស្រូបថាមពលព្រះអាទិត្យមួយកន្លែង នៅក្នុងការចាត់ចែងមួយដែលធានាឲ្យមានប្រាក់ចំណូលជាប្រចាំសម្រាប់គ្រួសារគាត់ ហើយទន្ទឹមនឹងផ្តល់ឲ្យអ្នកភូមិនូវ ប្រភពថាមពលដែលអាចជាវបាន និងដែលមានមេត្រីភាពជាមួយបរិស្ថាន។

ជាថ្នូរនឹងការអនុញ្ញាតឲ្យតម្លើងបរិក្ខារផលិតថាមពលព្រះអាទិត្យនៅក្រោយផ្ទះគាត់ លោក ជួប ផា ទទួលបានប្រាក់ចំណូល ៤០ ភាគរយ ពីសេវាបញ្ចូលភ្លើងអាគុយ។ ប្រាក់ចំណូល ៦០ ភាគរយ ដែលសល់ក្រៅពីនេះត្រូវបានជាផលចំណូលសម្រាប់គណៈកម្មការគ្រប់គ្រងស្ថានីយ៍ស្រូបថាមពលព្រះអាទិត្យដែលមានសមាសភាពជាតំណាងពី ការិយាល័យឃុំ និងអ្នកភូមិ ដើម្បីប្រើប្រាស់សម្រាប់ជាមូលនិធិថែទាំ និងអភិវឌ្ឍន៍ជាប្រយោជន៍របស់សហគមន៍នេះ។

លោកជួប ផា បានពោលថា "សេវាថ្មីនេះមានការនិយមកាន់តែច្រើនឡើងក្នុងចំណោមអ្នកភូមិ។ មូលហេតុមួយគឺថ្លៃបញ្ចូលអាគុយទាបជាងការបញ្ចូលដោយប្រើម៉ាស៊ីនភ្លើង"។គាត់បន្ថែមថាគាត់បញ្ឈប់ម៉ាស៊ីនភ្លើងរបស់គាត់ដែលដើរដោយប្រេងម៉ាស៊ូត តែថ្ងៃណាដែលខ្សត់ពន្លឺព្រះអាទិត្យតែប៉ុណ្ណោះ ជាពិសេសក្នុងរដូវវស្សា។

ថ្លៃបញ្ចូលអាគុយមានពី៥០០រៀលដល់៣.០០០រៀល អាស្រ័យលើសមត្ថភាពផ្ទុករបស់អាគុយ។ ប៉ុន្តែធៀបនឹងការប្រើប្រាស់ម៉ាស៊ីនភ្លើង ថ្លៃសម្រាប់ការបញ្ចូលអាគុយនីមួយៗទាបជាងមុន ៥០០រៀល ដែលជាទឹកប្រាក់តិចតួច ប៉ុន្តែជាចំនួនច្រើនសម្រាប់ប្រជាជនភាគច្រើនដែលរកស់ក្រោមបន្ទាត់ភាពក្រីក្រ ៣.៨៧១ រៀល (តិចជាង ១ដុល្លារអាមេរិក)ក្នុងមួយថ្ងៃ។

ស្ថានីយ៍ថាមពលព្រះអាទិត្យនីមួយៗមានសមត្ថភាពបញ្ចូលអាគុយចំនួន៥០ក្នុងមួយថ្ងៃ។ តាមទ្រឹស្តីចំនួននេះគ្រប់គ្រាន់សម្រាប់ផ្តល់ឲ្យគ្រួសារមួយជាមធ្យមនូវថាមពលសម្រាប់រយៈពេលមួយឆ្នាំ។

យោងតាមក្រុមប្រឹក្សាវិនិយោគកម្ពុជា សព្វថ្ងៃនេះមានគ្រួសារកម្ពុជាត្រឹម ២២,៤៧ ភាគរយ ប៉ុណ្ណោះដែលមានអគ្គិសនីប្រើប្រាស់។ក្នុងចំណោមគ្រួសារនៅ

*តទៅទំព័រទី ៣*

# ពីដីធ្លាប់មានគ្រាប់មីនទៅជាទីសុវត្ថិភាពសម្រាប់ដាំដំណាំ

សម្រាប់កសិករជាច្រើនដែលមានដីតិចតួចនៅភាគបូព៌ានៃប្រទេសកម្ពុជា ការដាំដំណាំអាចជារបរមួយដែលប្រថុយខ្លាំង។ មិនត្រឹមតែគ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះដែលនៅសេសសល់ពីសម័យសង្រ្គាមប៉ុណ្ណោះទេដែលជាមុខសញ្ញាមហន្តរាយចំពោះសុវត្ថិភាព ប៉ុន្តែវាក៏ជាឧបសគ្គចំពោះផលិតភាពកសិកម្មក្នុងការផ្តល់លទ្ធភាពដើម្បីទទួលបានប្រាក់ចំណូលច្រើននិងសន្តិសុខស្បៀងប្រសើរជាងមុនសម្រាប់គ្រួសារក្រីក្រផងដែរ។

នៅខេត្តបន្ទាយមានជ័យ តេង ឡូច អាយុ ៥៥ឆ្នាំ មានសេចក្តីរីករាយណាស់។ គ្រាប់មីនប្រឆាំងមនុស្ស និងមីនប្រឆាំងរថក្រោះសរុបចំនួនប្រាំបួនគ្រាប់ ត្រូវបានរកឃើញ ដោះ និងបំផ្លាញនៅស្រុកម៉ាឡៃ ដែលរួមទាំងនៅតាមចំណែកដីក្បែរផ្ទះរបស់គាត់ផងដែរ។

ឡូច បានពោលថា "ខ្ញុំធ្លាប់ជាស៊ីឈ្នួលគេដែលរួមទាំង ដាំដំណាំឲ្យអ្នកដទៃដែលជាម្ចាស់ដី និងបានទទួលកម្រៃត្រឹម១៦.០០០រៀល( ៤ដុល្លារអាមេរិក ) ក្នុងមួយថ្ងៃ។ ឥឡូវនេះ ខ្ញុំអាចដាំដំណាំនៅជិតផ្ទះនិងទទួលផលចំណូលពីដំណាំនេះ"។

តាមរយៈគម្រោងសម្អាតដើម្បីលទ្ធផល កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងដៃគូនានា បានជួយរដ្ឋាភិបាលកម្ពុជាក្នុងការបោសសំអាតគ្រាប់មីន នៅក្នុងខេត្តដែលមានគ្រាប់មីនបង្កប់ក្នុងដីច្រើនជាងគេនៃប្រទេសកម្ពុជា ពោលគឺ ខេត្តបាត់ដំបង បន្ទាយមានជ័យ និងប៉ៃលិន។ គម្រោងដែលមានទឹកប្រាក់ ២៥លានដុល្លារ ដែលបានទទួលការគាំទ្រដោយរដ្ឋាភិបាលអូស្រ្តាលី កាណាដា ស្វីស អូទ្រីស និងចក្រភពអង់គ្លេស បានជួយបោសសំអាតផ្ទៃដីប្រមាណ ៨៣គ.ម² តាំងពីឆ្នាំ ២០០៦មក។ គម្រោងនេះដែលសព្វថ្ងៃស្ថិតក្នុងជំហានទីពីរ និងបានអនុវត្តដោយអាជ្ញាធរសកម្មភាពមីន និងជួយជនរងគ្រោះកម្ពុជា ( CMAA ) បានរួមចំណែកក្នុង



Photot: UNDP Cambodia/Maria Frio

*ឡេន ភាព កំពុងមើលថែទាំដំណាំល្ងក្នុងចំការក្រោយផ្ទះរបស់គាត់ នៅខេត្តបាត់ដំបង។ កាលពីប៉ុន្មានឆ្នាំមុនដីនេះធ្លាប់មានគ្រាប់មីនតែឥឡូវត្រូវបានបោសសំអាតរួចតាមរយៈគម្រោង Clearing for Results ។*

ការកាត់បន្ថយជាបន្តបន្ទាប់ចំនួនអ្នករបួសដោយសារគ្រាប់មីននៅទូទាំងប្រទេសកម្ពុជា ពី១៨៨នាក់ នៅឆ្នាំ ២០០៦ មកត្រឹម ៤៨នាក់ នៅឆ្នាំ ២០១៣។

លើសពីនេះ ដីដែលបានបោសសំអាតរួចនៅឆ្នាំ ២០១១ចំនួន៨០ភាគរយនៅក្នុងខេត្តចំនួនបីឥឡូវនេះ កំពុងប្រើប្រាស់សម្រាប់គោលដៅកសិកម្មបើផ្អែកតាមការពិនិត្យតាមដានគម្រោងនៅក្រោយបានដោះមីនរួច។

គ្រួសារបែបនេះមួយដែលបានទទួលផលពីគម្រោងនេះ គឺគ្រួសាររបស់តេង ឡូច។

លោកបានពោលថា "ខ្ញុំអាចដាំដំឡូងមី និងស្រូវលើផ្ទៃដី១,៦ហិកតារបស់ខ្ញុំ។នៅឆ្នាំបន្ទាប់ ខ្ញុំរកបាន ៦៦៧ដុល្លារអាមេរិកពីដំណាំដំឡូង និងប្រមូលផលស្រូវបាន១០បាវ។ ខ្ញុំទុកមួយបាវសម្រាប់ខ្លួនឯង និងគ្រួសារខ្ញុំ ដែលគ្រប់គ្រាន់សម្រាប់បរិភោគពេញមួយឆ្នាំ។

នៅខេត្តបាត់ដំបង ស្ត្រីឈ្មោះ ឡេន ភាព ដែលឥឡូវនេះមានអាយុ ៣៦ឆ្នាំ បានដាំល្ង និងកូនស្វាយ នៅលើចំណែកដីទំហំ ២០០មx២៥ម នៅក្រោយផ្ទះរបស់គាត់ ដែលបានសំអាតពីគ្រាប់មីនតាមរយៈគម្រោងសំអាតដើម្បីលទ្ធផល។រដូវប្រមូលផលមកដល់ភាពអាចរកបានប្រាក់ចំណូលប្រមាណ ១៣៨ដុល្លាអាមេរិក ពីដំណាំល្ង និងរហូតដល់ ១.០៣១ដុល្លារអាមេរិក ពីផ្លែស្វាយ ដែលមិនមែនជាប្រាក់ចំណេញតិចតួចឡើយ សម្រាប់គាត់ដែលធ្លាប់រកបានត្រឹម៤.០០០រៀល ( ១ដុល្លា ) ក្នុងនាមជាងអ្នកស៊ីឈ្នួលរានឆ្ការព្រៃ។

ទាំងលោក តេង ឡូច និង ឡេន ភាព បានពោលថា ពួកគេប្រើប្រាស់ប្រាក់ដែលពួកគេរកបាន សម្រាប់ទិញសម្ភារៈចាំបាច់ អាហារ សម្លៀកបំពាក់ ឱសថ បង់ថ្លៃសម្រាប់កូនចូលរៀន ឬការចំណាយលើសេវាផ្សេងៗសម្រាប់គ្រួសារ។ តេង ឡូច បានលៃទុកប្រាក់ចំណូលរបស់គាត់មួយផ្នែកដើម្បីជួលត្រាក់ទ័រសម្រាប់ភ្ជួររាស់ដីនៅរដូវខាងមុខ។ ចំណែក ឡេន ភាព បានសន្សំប្រាក់ខ្លះៗ ដើម្បីជួលរថយន្តដឹកទំនិញ ដើម្បីដឹកទឹកពីទន្លេដែលនៅក្បែរនោះសម្រាប់ស្រោចដំណាំរបស់គាត់។

# យុទ្ធសាស្ត្រពាណិជ្ជកម្ម...

*តមកពីទំព័រទី ១*

ពេលដែលសំណៅមុន ពោលគឺ យុទ្ធសាស្ត្រសមាហរណកម្មការវិភាគពាណិជ្ជកម្ម ត្រូវបានចេញផ្សាយជាលើកដំបូង។សំណៅចុងក្រោយនេះបានគូសបញ្ជាក់អំពីកំណើនដែលកម្ពុជាសម្រេចបានចាប់ពីពេលនោះមកនៅក្នុងការប្រើប្រាស់ពាណិជ្ជកម្មជាយាននាំមកនូវកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ ក្នុងចំណោមប្រជាជនកម្ពុជា។ យុទ្ធសាស្ត្រនេះចែងថា ការនាំចេញទំនិញ និងសេវា បាននាំឲ្យមានកំណើនផលចំណូលពី៤,៩ពាន់លានដុល្លារអាមេរិកដល់៨,១ពាន់លានដុល្លារអាមេរិក ឬកំណើន ៦៥ ភាគរយ រវាងឆ្នាំ២០០៧ និង២០១១។ ក្រៅពីសម្លៀកបំពាក់និងទេសចរណ៍ ភាគចំណែកនៃការនាំចេញនៅក្នុងអំឡុងពេលនេះក៏បានកើនឡើងផងដែរពី ១៨ ដល់ ២៩ ភាគរយ។ ក្នុងចំណោមផលិតផលនាំចេញសំខាន់ៗទាំងនោះគឺ កង់ សមាសភាគអេឡិចត្រូនិក ស្បែកជើង កៅស៊ូធម្មជាតិ អង្ករនិងស្រូវ ដំឡូងមី ពោត និងសណ្តែកសៀង។

ប៉ុន្តែយុទ្ធសាស្ត្រនេះចង្អុលបង្ហាញពីកម្រិតជំនាញថ្នាក់កណ្តាល និងថ្នាក់ខ្ពស់ដែលនៅទន់ខ្សោយ និងដែលចាំបាច់សម្រាប់ដំណើរការផលិតកម្មកាន់តែទំនើប ដែលជាបញ្ហាគន្លឹះមួយរាំងស្ទះការបង្កើនផលិតភាព និងការវិនិយោគ ដែលអាចជួយឲ្យសេដ្ឋកិច្ចឈានទៅលំដាប់ខ្ពស់នៃខ្សែចង្វាក់តម្លៃ។

យុទ្ធសាស្ត្រនេះចែងថា "អាស្រ័យដោយមូលហេតុទាំងនេះ ប្រការសំខាន់គឺត្រូវដោះស្រាយភាពខ្វះចន្លោះរវាងជំនាញ នៅក្នុងចំណោមកម្លាំងពលករបច្ចុប្បន្ននេះ និងជំនាញដែលចាំបាច់សម្រាប់កន្លែងធ្វើការក្នុងពេលសព្វថ្ងៃ និងទៅអនាគត។"

ការពង្រឹងជំនាញតាមរយៈការបណ្តុះបណ្តាលបច្ចេកទេស និងការអប់រំវិជ្ជាជីវៈ និងការកែលម្អគុណភាពនៃកម្មវិធីអប់រំ ដើម្បីបំពេញតាមតម្រូវការទីផ្សារការងារ ស្ថិតក្នុងចំណោមគោលដៅនានានៃយុទ្ធសាស្ត្រនេះ។ យុទ្ធសាស្ត្រនេះចែងថា ជំនាញ និងការអប់រំដែលមានគុណភាពខ្ពស់ជាងនេះ មានសារៈសំខាន់ណាស់សម្រាប់ពង្រឹងឱកាសដើម្បីទទួលបានការងារដែលផ្តល់កម្រៃប្រសើរជាងមុន ទាំងសម្រាប់អ្នកកំពុងធ្វើការបច្ចុប្បន្ននេះ និងអ្នកចំណូលថ្មីនៅក្នុងទីផ្សារការងារ។

យុទ្ធសាស្ត្រនេះចែងថា "ជំនាញខ្ពស់ជាងមុនដែលអាចឲ្យជនកម្ពុជាទទួលរ៉ាប់រងការងារដែលបច្ចុប្បន្នកាន់កាប់ដោយបុគ្គលិកបរទេស នឹងជួយកាត់បន្ថយថ្លៃចំណាយចំពោះសហគ្រាស និងពង្រឹងភាពប្រកួតប្រជែងរបស់សហគ្រាសទាំងនោះ។"

យុទ្ធសាស្ត្រ CTIS ត្រូវបានរៀបចំឡើងនៅក្រោមការដឹកនាំរបស់ក្រសួងពាណិជ្ជកម្ម ដោយមានការគាំទ្រពីកម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម (Enhanced Integrated Framework) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងដៃគូអភិវឌ្ឍន៍ដទៃទៀត។

លោកស្រី ក្លែរ វ៉ាន់ ដឺ វ៉ារេន អ្នកសម្របសម្រួលអង្គការសហប្រជាជាតិនៅកម្ពុជា មានប្រសាសន៍នៅក្នុងសុន្ទរកថាក្នុងពិធីប្រកាសនេះថា "ក្នុងចំណោមអាទិភាពទាំងអស់នៅក្នុងយុទ្ធសាស្ត្រCTIS,របៀបវារៈមូលធនមនុស្សមានសារៈសំខាន់ដោយឡែក។ ដើម្បីឲ្យជនកម្ពុជាទទួលផលពីកំណើនសេដ្ឋកិច្ច មូលធនមនុស្សមានសារៈសំខាន់ខ្លាំងណាស់។"

# យុវជនស្វែងយល់ដឹងជាងមុនអំពីជីវភាពជាពលរដ្ឋស៊ីវិល

**ភ្នំពេញ**-ប៉ុន្មានឆ្នាំមុននេះពលរដ្ឋវ័យក្មេងជាច្រើននៅកម្ពុជាត្រូវបានគេអង្កេតរកឃើញថាមានការយល់ដឹងតិចតួចអំពីសារៈសំខាន់នៃការចូលរួមក្នុងនាមជាជនស៊ីវិល ដើម្បីដោះស្រាយបញ្ហានានាដែលទាក់ទងនឹងពួកគេ និងសហគមន៍របស់ពួកគេ។ ស្ថានភាពបានចាប់ផ្តើមប្រែប្រួលប្រសើរឡើងហើយឥឡូវនេះ។ ពលរដ្ឋវ័យក្មេងជាច្រើនបានបង្ហាញពីចំណាប់អារម្មណ៍កាន់តែច្រើនក្នុងការរួមចំណែកក្នុងកិច្ចការស៊ីវិលនៅក្រោយពួកគេបានប្រឡូកនៅក្នុងកម្មវិធីឡូយ៩ ដែលជាកិច្ចផ្តួចផ្តើមផ្តល់ប្រព័ន្ធព័ត៌មានចម្រុះស្តីពីការអប់រំអំពីកិច្ចការស៊ីវិលដល់យុវជន។

នេះគឺជាសេចក្តីសន្និដ្ឋានមួយផ្អែកលើរបកគំហើញនៃការអង្កេតអំពីឥទ្ធិពលរបស់កម្មវិធីឡូយ៩ដែលត្រូវបានអនុវត្តដោយកម្មវិធី BBC Media Action តាមរយៈមូលនិធិពីស៊ុយអែដ និងយូអិនឌីភី។

ការអង្កេត –"ឡូយ៩៖ ការផ្សព្វផ្សាយ និងប្រឡូកយុវជនកម្ពុជាឲ្យចូលរួមនៅក្នុងកិច្ចការស៊ីវិល" - បានឲ្យដឹងថាពលរដ្ឋវ័យក្មេងនៅកម្ពុជាមានការយល់ដឹងកម្រិតខ្ពស់អំពីឱកាសសម្រាប់ការចូលរួមក្នុងការងារស៊ីវិល។ យុវជនភាគច្រើន(៨៩%)បានដឹងថា យ៉ាងហោចណាស់មានឱកាសម្តងសម្រាប់ការចូលរួមដូចជាការរួមចំណែកក្នុងផែនការអភិវឌ្ឍន៍ឃុំ សេវាសហគមន៍ ការចូលរួមក្នុងសមាគមសាសនា។ ទោះជាយ៉ាងណាក៏ដោយ យុវជនដែលបានដឹងពីកម្មវិធីឡូយ ៩ បានបង្ហាញពីការយល់ដឹងកាន់តែច្រើនអំពីឱកាសសម្រាប់ការចូលរួមក្នុងការងារសហគមន៍ ជាងអ្នកដែលមិនបានដឹងពីកម្មវិធីនេះ។ ជាក់ស្តែង ពួកគេមិនទំនងជាមិនបានដឹងអំពីឱកាសណាមួយឡើយ ធៀបនឹងយុវជនដែលមិនបានដឹងអំពីកម្មវិធីនេះ( ៦%ធៀបនឹង ១៨% )។ យុវជនដែលបានដឹងពីកម្មវិធីឡូយ៩ ទំនងជាបានចូលរួមក្នុងការងារសហគមន៍តាមរយៈសាលារៀន ( ៣៦%សម្រាប់អ្នកដែលបានដឹង ធៀបនឹង២៣% សម្រាប់អ្នកដែលមិនបានដឹងពីកម្មវិធីនេះ ) បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលអំពីការដឹកនាំ ( ១៩% ធៀបនឹង ១៣% ) និងការចូលរួមនៅក្នុងអង្គការនយោបាយ (២៧% ធៀបនឹង ១៩% )។

កម្រិតនៃការចូលរួមនៅក្នុងដំណើរការបោះឆ្នោតនៃអ្នកដែលបានដឹងអំពីកម្មវិធីឡូយ៩ ក៏មានកម្រិតខ្ពស់ផងដែរធៀបនឹងអ្នកដែលមិនបានដឹងពីកម្មវិធីនេះ។ ការអង្កេតនេះបង្ហាញអំពីសមាមាត្រខ្ពស់ជាងនៃយុវជនដែលបានដឹងពីកម្មវិធីនេះ ធៀបនឹងយុវជនដែលមិនបានដឹង ដូចជា បានចូលរួមបោះឆ្នោតនៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ ( ៥២% ធៀបនឹង ៤៤% )។

កម្ពុជាមានប្រជាពលរដ្ឋក្នុងវ័យក្មេងជាងគេនៅអាស៊ីអាគ្នេយ៍។ កម្មវិធីឡូយ៩ត្រូវបានប្រកាសជាផ្លូវការនៅខែមករា ឆ្នាំ២០១២ បន្ទាប់ពីមានការសិក្សាអំពីចំណេះដឹង ឥរិយាបថ និងការអនុវត្ត ដែលបានរកឃើញអំពីការយល់ដឹងកម្រិតទាបក្នុងចំណោមពលរដ្ឋវ័យក្មេងជាច្រើនអំពីសារៈសំខាន់នៃជីវភាពជាជនស៊ីវិល និងមុខងារនៃស្ថាប័នសំខាន់ៗរបស់ប្រទេស ដូចជារដ្ឋសភា និងក្រុមប្រឹក្សាឃុំ។ ពលរដ្ឋវ័យក្មេងជាច្រើនក៏ត្រូវបានរកឃើញថា មានការលំបាកក្នុងការលើកឡើងនូវបញ្ហានានាដែលទាក់ទងនឹងពួកគេ និងសហគមន៍របស់ពួកគេផងដែរ។

នៅក្នុងការព្យាយាមកាត់បន្ថយភាពខ្វះចន្លោះនៃចំណេះដឹង និងលើកទឹកចិត្តពលរដ្ឋវ័យក្មេងឲ្យចូលរួមយ៉ាងសកម្មនៅក្នុងជីវភាពជាពលរដ្ឋ កម្មវិធីឡូយ៩ ប្រើប្រាស់វេទិកាព័ត៌មានចម្រុះដែលរួមទាំងកម្មវិធីភាគតាមទូរទស្សន៍ការទូរស័ព្ទចូលក្នុងកម្មវិធីតាមវិទ្យុសកម្មភាពអនុវត្តផ្ទាល់ និងបណ្តាញព័ត៌មានសង្គម។ តាំងពីពេលនោះមក កម្មវិធីនេះបានផ្សព្វផ្សាយដល់ពលរដ្ឋវ័យក្មេងច្រើនជាង ២លាននាក់ ដែលឆ្លើយតបដោយជោគជ័យតបនឹងគោលដៅដែលបានគ្រោងទុកពីដំបូង។

របាយការណ៍នៃការអង្កេតនេះត្រូវបានចេញផ្សាយនៅថ្ងៃទី ១៧ ខែ មីនា ពោលគឺ បីថ្ងៃមុនពេលចាប់ផ្តើមកម្មវិធីឡូយ៩វគ្គទីបី ដែលផ្តោតលើប្រធានបទនៃការដោះស្រាយទំនាស់។ បើទោះជាមានការកែលម្អក៏ដោយ ការអង្កេតនេះបានបង្ហាញថា មានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីអាចបង្កើតទំនុកចិត្ត ដើម្បីបង្កើនការយល់ដឹងអំពីជីវភាពជាជនស៊ីវិល និងការចូលរួមនៅក្នុងវិស័យនានាដូចជាប្រជាធិបតេយ្យនិងការធ្វើសេចក្តីសម្រេចសិទ្ធិរបស់ពលរដ្ឋ តួនាទីរបស់រដ្ឋសភា និងក្រុមប្រឹក្សាឃុំ សារៈសំខាន់នៃការចូលរួម និងសមភាព។

ការអង្កេតនេះបង្ហាញថា "កម្មវិធីនេះអាចបង្កើនចំណេះដឹង និងការយល់ដឹង ទំនុកចិត្តក្នុងការសំដែងមតិ និងអាចមានឥទ្ធិពលមិនត្រឹមតែក្នុងចំណោមពលរដ្ឋវ័យក្មេងអំពីឱកាសក្នុងការចូលរួមប៉ុណ្ណោះទេ ប៉ុន្តែបម្លែងទៅជាការចូលរួមកាន់តែច្រើនឡើងនៅក្នុងសហគមន៍ និងការចូលរួមក្នុងការបោះឆ្នោតផងដែរ"។

# បន្ទះស្រូបពន្លឺព្រះអាទិត្យ...

*តមកពីទំព័រទី ១*

តាមជនបទទាំងនោះមានតែ១៣ភាគរយប៉ុណ្ណោះដែលមានអគ្គិសនីប្រើប្រាស់ធៀបនឹង ៥៤ភាគរយ សម្រាប់គ្រួសារនៅតាមទីក្រុង។ រដ្ឋាភិបាលមានគោលដៅផ្តល់អគ្គិសនីសម្រាប់គ្រួសារនៅជនបទឲ្យបានចំនួន ៧០ ភាគរយ រហូតដល់ឆ្នាំ ២០៣០។

បើតាមការចងចាំរបស់ពួកគេ អ្នកភូមិនៅភូមិពោធ៌ និងត្របែក បានពឹងផ្អែកលើអាគុយរថយន្តសម្រាប់ការបំភ្លឺជារៀងរហូតមក។ ប៉ុន្តែនៅពេលថ្មីៗនេះ បង្គោលអគ្គិសនីត្រូវបានតម្លើងនៅតាមដងផ្លូវលំដីក្រហមទៅកាន់ភូមិនេះដែលផ្តល់ឲ្យអ្នកភូមិនូវក្តីសង្ឃឹមថា នៅថ្ងៃមួយ ពួកគេនឹងបានទទួលថាមពលអគ្គិសនីទៀងទាត់សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ។ អ៊ុំស្រី ភេម ជា បាន ពោលថា អាគុយនឹងបន្តជាជម្រើសតែមួយគត់មួយរយៈទៀតសម្រាប់គាត់ ទម្រាំនឹងមានប្រព័ន្ធអគ្គិសនីមកដល់ក្នុងភូមិ។

គាត់បានពោលថា "វាក៏អាស្រ័យផងដែរលើថ្លៃអគ្គិសនីពីបណ្តាញចែកចាយ។ ប្រសិនបើមានថ្លៃខ្ពស់ ខ្ញុំអាចនៅតែបន្តពឹងផ្អែកលើអាគុយរបស់ខ្ញុំតទៅទៀត។

ស្ថានីយ៍ថាមពលអគ្គិសនីពីព្រះអាទិត្យទាំងពីរនេះបានទទួលការគាំទ្រពីកម្មវិធីជំនួយឥតសំណងនៃមូលនិធិបរិស្ថានពិភពលោក (Global Environment Facility Small Grants Programme) តាមរយៈគម្រោងមួយដែលគ្រប់គ្រងដោយយូអិនឌីភី។ គម្រោងនេះជួយផ្តល់ឲ្យគ្រួសារតាមជនបទនូវលទ្ធភាពទទួលបានថាមពលស្អាតដែលរួមចំណែកក្នុងការដោះស្រាយបញ្ហាបំភាយកាបូន ជាពិសេសពីម៉ាស៊ីនភ្លើងនៅមូលដ្ឋាន។

# ផ្តើមដំណើរការគម្រោងត្រៀមលក្ខណៈដើម្បី REDD+

**ភ្នំពេញ** - គម្រោងដែលមានគោលដៅកាត់បន្ថយការបំភាយកាបូនក្នុងវិស័យព្រៃឈើនៅកម្ពុជា ឥឡូវនេះឈានចូលក្នុងដំណាក់កាលអនុវត្តហើយ បន្ទាប់ការប្រកាសចាប់ផ្តើមកាលពីថ្ងៃសុក្រទី១៤ខែមីនា។គម្រោងត្រៀមលក្ខណៈសម្រាប់ REDD+ នៅក្រោមមូលនិធិភាពជាដៃគូកាបូនព្រៃឈើដែលគេស្គាល់ថាជាគម្រោងFCPFត្រូវបានបង្កើតឡើងដើម្បីជួយប្រទេសកម្ពុជាត្រៀមខ្លួនដោះស្រាយបញ្ហានៃការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ។

អ្នកចូលរួមប្រមាណ ១០០នាក់ មកពីក្រសួងពាក់ព័ន្ធនៃរដ្ឋាភិបាល ទីភ្នាក់ងារអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល បានចូលរួមនៅក្នុងកិច្ចប្រជុំនេះដើម្បីធ្វើការពិភាក្សាអំពីគោលបំណង និងសកម្មភាពចំបងៗនៃគម្រោង។

ថ្លែងក្នុងសុន្ទរកថាទៅកាន់ពិធីនោះ លោកស្រី ក្លែរ វ៉ាន់ ឌឹ វ៉ារេន អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា បានអធិប្បាយគម្រោងនេះថា "មានការពាក់ព័ន្ធជាខ្លាំង" ចំពោះកម្ពុជា ដែលបានរងការបាត់បង់ព្រៃឈើក្នុងអត្រាគួរឲ្យព្រួយបារម្ភនៅក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ។

លោកស្រីមានប្រសាសន៍ថា "ការបាត់បង់ព្រៃឈើ មិនត្រឹមតែបង្កើនឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុប៉ុណ្ណោះទេ វាក៏បង្កឥទ្ធិពលអវិជ្ជមានមកលើរបរចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន និងគំរាមកំហែងមកលើជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីដែលមានសារៈសំខាន់ជាអាយុជីវិតដែលនៅកម្ពុជា។ ប្រព័ន្ធអេកូឡូស៊ីទាំងនោះគឺជាទីជម្រកសម្រាប់ប្រទេសជិតផុតពូជលើពិភពលោកផងដែរ"។

កម្ពុជាត្រូវបានចាត់ជាប្រទេសមួយដែលមាន"គម្របព្រៃកម្រិតខ្ពស់ ប៉ុន្តែក៏មានអត្រាខ្ពស់នៃការបាត់បង់ព្រៃឈើផងដែរ"។ យោងតាមការវាយតម្លៃធនធានព្រៃឈើដែលបានធ្វើឡើងដោយអង្គការស្បៀង និងកសិកម្ម (FAO) នៅឆ្នាំ ២០១០ កម្ពុជាមានព្រៃឈើប្រមាណ ១០,១លានហិកតា ដែលត្រូវជា ៥៧% នៃផ្ទៃប្រទេសទាំងមូល។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងទសវត្សរ៍កន្លងទៅថ្មីៗនេះ កម្ពុជាបានជួបប្រទះនឹងការបាត់បង់ព្រៃឈើតាមអត្រាយ៉ាងខ្ពស់។ ការបាត់បង់ព្រៃឈើបានកើតឡើងតាមអត្រាប្រមាណ ១,២% ក្នុងមួយឆ្នាំ នៅរវាងឆ្នាំ ២០០៥ និង ២០១០។

គម្រោង FCPF បានបង្កើតឡើងដោយធនាគារពិភពលោកនៅឆ្នាំ ២០០៨ ដើម្បីគាំទ្រដល់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការត្រៀមខ្លួនសម្រាប់ការអនុវត្ត REDD+។ អង្គការយូអិនឌីភី ត្រូវបានជ្រើសរើសជាដៃគូមួយសម្រាប់ការសម្រេចលទ្ធផលនៃគម្រោងនេះនៅកម្ពុជា។ គម្រោងនេះនឹងត្រូវអនុវត្តក្រោមភាពជាដៃគូជាមួយរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

គម្រោងនេះមានគោលដៅសម្រេចលទ្ធផលដូចតទៅ៖

- បង្កើតឲ្យមានរចនាសម្ព័ន្ធគ្រប់គ្រងដើម្បីការត្រៀមលក្ខណៈរបស់ជាតិសម្រាប់ REDD+
- បង្កើតយុទ្ធសាស្ត្រជាតិ REDD+ និងក្របខ័ណ្ឌអនុវត្ត
- កសាងសមត្ថភាពនៅថ្នាក់ក្រោមជាតិដើម្បីត្រៀមលក្ខណៈសម្រាប់ REDD+ និង
- បង្កើតប្រព័ន្ធវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV) នៅក្រោមកម្មវិធី REDD+

គម្រោងនេះមានរយៈពេលបីឆ្នាំកន្លះ គិតចាប់ពីដើមឆ្នាំ ២០១៤ រហូតដល់ពាក់កណ្តាលឆ្នាំ ២០១៧។ រហូតដល់ចុងឆ្នាំ ២០១៤ យុទ្ធសាស្ត្រជាតិ REDD+ ត្រូវបានរំពឹងថានឹងបានរៀបចំជាស្រេច ដែលចែងអំពីបញ្ហាគន្លឹះនានាដូចតទៅ៖ ប្រព័ន្ធតាមដានរបស់ជាតិ វិធានការនានាដើម្បីវាស់ការបាត់បង់ព្រៃឈើ ការចែកផល ប្រព័ន្ធសុវត្ថិភាព យន្តការបណ្តឹងសារទុក្ខ និងការបង្កើតសមត្ថភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

លោកស្រី វ៉ាន់ ឌឹ វ៉ារ៉េន អ្នកសម្របសម្រួលអង្គការសហប្រជាជាតិនៅកម្ពុជាមានប្រសាសន៍ថាដោយមានរដ្ឋាភិបាលក្នុងតួនាទីនាំមុខសកម្មភាពប្រកបដោយសារសម្របសម្រួលបានល្អ និងការចូលរួមប្រកបដោយប្រសិទ្ធភាពពីអ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់ "មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការអនុវត្តគម្រោង FCPFឲ្យបានជោគជ័យ" ។

# សមភាពសម្រាប់ស្ត្រី គឺជាវឌ្ឍនភាពសម្រាប់ទាំងអស់គ្នា!

ដោយលោកស្រី ក្លែរ វ៉ាន ឌឺ វ៉ារេន
អ្នកសម្របសម្រួលសហប្រជាជាតិនៅកម្ពុជា
បទអត្ថាធិប្បាយសម្រាប់ប្រារព្ធ ទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ ២០១៤



Photo: UNDP Cambodia/ Thomas Cristofoletti

*ស្ត្រីជាសិក្ខាកាមកំពុងហ្វឹកហាត់ផលិតកម្មវិធីវិទ្យុសហគមន៍ស្ត្រីនៅខេត្តក្រចេះ។ កម្មវិធីនេះ សំដៅជួយលើកកំពស់ជីវភាពរស់នៅរបស់ស្ត្រីក្នុងតំបន់គោលដៅតាមរយៈការបង្កើនលទ្ធភាព អនុវត្តន៍សិទ្ធិរបស់ខ្លួនឲ្យបានពេញលេញ និងបន្ថយគម្លាតក្នុងការទទួលបានព័ត៌មានរវាងបុរសនិងស្ត្រី។*

ទិវានារីអន្តរជាតិ គឺជាឱកាសមួយដើម្បីអបអរសាទរវឌ្ឍនភាពដែលកម្ពុជាបានធ្វើឡើងឆ្ពោះទៅរកការផ្តល់ភាពអង់អាចដល់ស្ត្រី និងសមភាពយេនឌ័រ។ សមភាពសម្រាប់ស្ត្រី និងក្មេងស្រីគឺជាសិទ្ធិមនុស្សមួយ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជា និងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលកម្ពុជាបានផ្តល់សច្ចាប័ន។ ការធានាសមភាពយេនឌ័រ មានអានុភាពនៃការផ្លាស់ប្តូរដ៏ខ្លាំងក្លាមួយមកលើវឌ្ឍនភាពនៃការអភិវឌ្ឍទាំងមូល។

នៅក្នុងការផ្តល់អាទិភាពអភិបាលកិច្ចល្អនៅក្នុងយុទ្ធសាស្ត្រចតុកោណ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ពីទិសដៅសម្រាប់កម្ពុជាដើរឆ្ពោះទៅរកគោលដៅដែលបានកំណត់នៃកំណើន ការងារ សមធម៌ និងប្រសិទ្ធផល។ នៅក្នុងទិសដៅនេះ សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី និងក្មេងស្រី គឺជាកត្តាកំណត់ដ៏សំខាន់ថាតើការអភិវឌ្ឍនឹងមានលក្ខណៈរួមបញ្ចូលគ្នា និងប្រកបដោយចីរភាព។ជាការពិតគោលដៅអភិវឌ្ឍន៍របស់កម្ពុជាអាចសម្រេចទៅបាន លុះត្រាតែមានការចូលរួមពេញលេញពីស្ត្រី និងក្មេងស្រី។

ប្រជាពលរដ្ឋជាស្ត្រីវ័យក្មេងរបស់កម្ពុជា មានសក្តានុពលក្នុងកាអភិវឌ្ឍតែយ៉ាងណាក៏ដោយក៏សក្តានុពលរបស់ស្ត្រីមិនទាន់បានទទួលស្គាល់នៅឡើយ។នៅពេលដែលក្មេងស្រីមានភាពស្មើគ្នាជាមួយក្មេងប្រុសដូចជាសុវត្ថិភាព ការទទួលបានការអប់រំ និងសុខភាព ពួកគេធំឡើងទៅជាស្ត្រីដែលបំពេញតួនាទីនានាដែលផ្តល់ផលប្រយោជន៍ដល់សង្គម និងសេដ្ឋកិច្ចដែលមានលក្ខណៈកាន់តែល្អប្រសើរជាងក្មេងស្រីប្រឈមវិសមភាពបែបនេះ។ ការវិនិយោគទៅលើក្មេងស្រីនិងស្ត្រីជួយពួកគេឲ្យបំពេញតួនាទីដឹកនាំក្នុងសង្គមនិងធ្វើឲ្យពួកគេក្លាយជាកត្តាជំរុញកំណើនសេដ្ឋកិច្ចដែលជាហេតុធ្វើកាន់តែប្រសើរនូវបរិយាកាសសម្រាប់ការចូលរួម និងភាពជាតំណាងរបស់ស្ត្រីនៅក្នុងអភិបាលកិច្ចប្រជាធិបតេយ្យ។

វិសមភាពយេនឌ័រ ត្រូវតែដោះស្រាយដើម្បីអត្ថប្រយោជន៍ទាំងឡាយដែលស្ត្រីនិងក្មេងស្រីត្រូវទទួលបាន។ នៅក្នុងប្រទេសកម្ពុជា ទោះបីជាមានភាពជឿនលឿនយ៉ាងច្រើននៅក្នុងការកាត់បន្ថយភាពក្រីក្រ (ពី ៥៣,២% នៃប្រជាពលរដ្ឋក្នុងឆ្នាំ២០០៤ មកដល់ ២០,៥% ក្នុងឆ្នាំ ២០១១) ក៏ដោយ ក៏អាហារូបត្ថម្ភរបស់ស្ត្រីនិងកុមារ នៅតែជាក្តីកង្វល់មួយ ហើយភាគរយនៃកុមារដែលមានបញ្ហាក្រិនធ្ងន់ធ្ងរ និងខ្វះទម្ងន់ នៅតែខ្ពស់។បើទោះជាសមភាពយេនឌ័រត្រូវបានសម្រេចបាននៅក្នុងការចូលរៀននៅថ្នាក់បឋមសិក្សាក្តី គម្លាតនៅតែមាននៅក្នុងការសិក្សាជាន់ខ្ពស់ ដោយក្មេងស្រីនៅតែឈប់រៀនជាងក្មេងប្រុសក្នុងនោះ ក្មេងប្រុសដែលចូលរៀននៅថ្នាក់មធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា មានចំនួនច្រើនជាងក្មេងស្រីចំនួនប្រមាណ ១៣%។ សុខភាពរបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជាមានភាពប្រសើរច្រើនជាងមុន។ អត្រាមរណភាពមាតាបានធ្លាក់ចុះក្នុងរយៈមួយទសវត្សរ៍កន្លងមកនេះ ដោយស្ត្រីបានទទួលកាន់តែច្រើនថែមទៀតនូវការថែទាំសុខភាពក្នុងពេលមានផ្ទៃពោះ និងការសម្រាល ហើយស្ត្រីកាន់តែច្រើនប្រើមធ្យោបាយការពារកំណើត។ យ៉ាងណាក្តី សម្រាប់ស្ត្រីវ័យក្មេង លទ្ធភាពបង្កកំណើតមិនបានធ្លាក់ចុះទេ ហើយក្មេងស្រីជំទង់ដែលជាអ្នកក្រីក្រនិងមានការអប់រំតិចហាក់ដូចជាឆាប់មានផ្ទៃពោះនៅពេលដែលពួកគេមិនទាន់បានត្រៀមខ្លួនរួចរាល់ដើម្បីធ្វើជាម្តាយនៅឡើយ។ ខណៈដែលមានកំណើនយ៉ាងច្រើននៅក្នុងការងារដែលមានប្រាក់ឈ្នួលរបស់ស្ត្រីនៅក្នុងវិស័យឧស្សាហកម្ម (ពីចំណែក ៤៤% ក្នុងឆ្នាំ២០០៥ ដល់ ៧០,៨% ក្នុងឆ្នាំ២០១១) ស្ត្រីទំនងជាស្ថិតនៅក្នុងការងារដែលងាយរងគ្រោះ ៩% ខ្ពស់ជាងបុរស ហើយនិងទំនងជារកប្រាក់ចំណូលជាមធ្យមបាន ២៧% តិចជាងបុរសទៅវិញ។ នៅក្នុងការបោះឆ្នោតជាតិឆ្នាំ២០១៣ របស់កម្ពុជា សមភាពយេនឌ័រនៅស្ថានីយបោះឆ្នោត (ជាង ៥០%) មិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសភាជាតិទេ (ដោយស្ត្រីបានតែ ២០% នៃអាសនៈប៉ុណ្ណោះ)។

ជាការពិតស្ត្រីទទួលបានអត្ថប្រយោជន៍ពីផ្លែផ្កានៃវឌ្ឍនភាពតិចជាង និងទទួលបានឱកាសតិចជាងក្នុងការកែលម្អជីវភាពរបស់ពួកគេហើយក្នុងពេលជាមួយគ្នានោះ ពួកគេកាន់តែងាយរងគ្រោះ ឬប្រឈមនឹងការលំបាក ផងដែរ។ ការសិក្សាថ្នាក់តំបន់របស់អង្គការសហប្រជាជាតិនាពេលថ្មីៗនេះបង្ហាញថា អំពើហិង្សាលើស្ត្រីគ្រប់ទម្រង់កំពុងតែរីករាលដាល រួមទាំងអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈផង។ បន្ថែមពីលើនេះ ស្ត្រីដែលស្ថិតនៅក្នុងក្រុមងាយរងគ្រោះដូចជាស្ត្រីដែលរស់ជាមួយភាពពិការ ស្ត្រីរស់នៅជាមួយមេរោគអេដស៍ ឬស្ត្រីជនជាតិដើមភាគតិច ប្រឈមមុខនឹងការរើសអើងនៅតាមកម្រិតថ្នាក់ផ្សេងៗជាច្រើន។

វិសមភាពទាំងនេះចាំបាច់ត្រូវតែដោះស្រាយដើម្បីឲ្យសក្តានុពលរបស់ក្មេងស្រីកម្ពុជាបច្ចុប្បន្នក្លាយទៅជាការពិតក្នុងអាយុជីវិតរបស់ស្ត្រីកម្ពុជានាពេលអនាគត។ សមភាពសម្រាប់ក្មេងស្រី និងស្ត្រី គឺជាវឌ្ឍនភាពសម្រាប់ពលរដ្ឋកម្ពុជាទាំងអស់។ នៅក្នុងសេចក្តីថ្លែងការណ៍សម្រាប់ទិវានារីអន្តរជាតិ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានសង្កត់ធ្ងន់លើសារយ៉ាងច្បាស់មួយ គឺ *"[...]សម្រាប់ក្មេងស្រីគ្រប់រូបដែលកើតថ្ងៃនេះ ហើយសម្រាប់ស្ត្រី និងក្មេងស្រីគ្រប់រូបក្នុងពិភពលោក ការសម្រេចបានសិទ្ធិមនុស្ស និងសមភាពវាមិនមែនជាក្តីសុបិននោះទេ វាគឺជាកាតព្វកិច្ចរបស់រដ្ឋាភិបាល អង្គការសហប្រជាជាតិ និងមនុស្សជាតិគ្រប់រូប។ [...]សម្រាប់បុរស និងក្មេងប្រុសរបស់ខ្ញុំ ចូរនាំគ្នាបំពេញតួនាទីរបស់អ្នក។ យើងទាំងអស់គ្នាទទួលបានអត្ថប្រយោជន៍ នៅពេលស្ត្រី និងក្មេងស្រី - ម្តាយ បងប្អូនស្រី មិត្តភក្តិ និងសហសេវិករបស់អ្នកអាចសម្រេចបានសក្តានុពលពេញលេញរបស់ពួកគេ"។*

ទោះបីជាគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ អំពាវនាវឲ្យមានសមភាពយេនឌ័រ វាមិនបានដោះស្រាយតម្រូវការឲ្យបានច្បាស់លាស់សម្រាប់ការផ្លាស់ប្តូរនៅក្នុងទំនាក់ទំនងយេនឌ័រឡើយ។ជាជាងផ្តោតទៅលើមូលហេតុនៃវិសមភាពយេនឌ័រ កន្លងមក គេបែរជាផ្តោតទៅលើផលវិបាករបស់វាទៅវិញ។ ដូច្នេះ នៅក្នុងការកសាងអភិបាលកិច្ចល្អ និងនៅក្នុងដោះស្រាយវិសមភាពយេនឌ័រ កម្ពុជាមានទាំងឱកាស និងតម្រូវការចាំបាច់ដើម្បីដោះស្រាយកត្តាជំរុញជាលក្ខណៈរចនាសម្ព័ន្ធនៃវិសមភាពយេនឌ័រ ដែលរួមមានបទដ្ឋាន អាកប្បកិរិយា និងជំនឿ ដែលជំរុញឲ្យមានការរើសអើងយេនឌ័រ។ ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនាពេលខាងមុខ (២០១៦-២០១៨) នឹងផ្តល់នូវកាលានុវត្តភាពដ៏ល្អប្រសើរមួយដើម្បីធ្វើសកម្មភាពក្នុងរយៈពេលប្រាំឆ្នាំបន្ទាប់។ ដោយសម្លឹងហួសពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ កម្ពុជាមានលទ្ធភាពល្អជាពិសេសដើម្បីបំពេញការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះសិទ្ធិមនុស្ស និងសមភាពយេនឌ័រ ដោយបង្កើន សម្លេង ជម្រើស និងសុវត្ថិភាពសម្រាប់ស្ត្រី និងក្មេងស្រីកម្ពុជាគ្រប់រូប។ជាមួយការផ្តោតយកចិត្តទុកដាក់ ការឆ្លើយតប និងទប់ស្កាត់អំពើហិង្សា ដោយផ្តល់ភាពអង់អាចដល់ស្ត្រីតាមច្បាប់ និងផ្នែកសេដ្ឋកិច្ច និងដោយពង្រឹងភាពជាអ្នកដឹកនាំ និងការចូលរួមរបស់ស្ត្រីនៅក្នុងជីវិតសាធារណៈ កម្ពុជាអាចអនុវត្តរបៀបវារៈអភិវឌ្ឍន៍ដែលឆ្លើយតបនឹងយេនឌ័រដើម្បីឲ្យមានការផ្លាស់ប្តូរ។ ធ្វើដូច្នេះ កម្ពុជានឹងធានាថា ការអភិវឌ្ឍគឺជាវឌ្ឍនភាពសម្រាប់ទាំងអស់គ្នា។

អាគារលេខ ៥៣ វិថី ប៉ាស្ទ័រ
សង្កាត់ បឹងកេងកង
ប្រអប់សំបុត្រលេខ ៨៧៧
ក្រុងភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ ៖ +855 (0) 23 216 167
ទូរសារ ៖ +855 (0) 23 216 257
អ៊ីម៉ែល ៖ registry.kh@undp.org
www.kh.undp.org
www.facebook.com/UNDPCambodia
www.twitter.com/UNDPCambodia